**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ៤៨០៧ ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ហៅកាត់ថា«**គ.ក.ស.ក.**»។

**ប្រការ២.-**

«**គ.ក.ស.ក.**»ត្រូវមានគណនេយ្យភាពផ្ទាល់ចំពោះក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌសាមី។

**ប្រការ៣.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំឱ្យមាន«**គ.ក.ស.ក.**»ដែលមានសិទ្ធិ និងមានភារកិច្ចផ្ដល់យោបល់ និងលើកអនុសាសន៍ ជូនក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវជន និងកុមារ ព្រមទាំងការងារសេវាសង្គមពាក់ព័ន្ធ នៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**ជំពូកទី២**

**សមាសភាព រចនាសម្ព័ន្ធ និងភារកិច្ចរបស់«គ.ក.ស.ក.»**

**ប្រការ៤.-**

«**គ.ក.ស.ក.**»នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត មានសមាសភាព ដូចខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាជាស្ត្រីដែលជ្រើសរើសដោយក្រុមប្រឹក្សា ប្រធាន
- សមាជិកក្រុមប្រឹក្សាដែលជ្រើសរើសដោយក្រុមប្រឹក្សា អនុប្រធាន
- អភិបាលរងជាស្ត្រីនៃគណៈអភិបាលរាជធានី ខេត្ត ចំនួន១រូប អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី អនុប្រធានអចិន្ត្រៃយ៍
- នាយករងរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត ចំនួន១រូប សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរផែនការ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សមាជិក

- ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត សមាជិក
- ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត សមាជិក
- នាយក ឬនាយករងទីចាត់ការអន្តរវិស័យនៃរដ្ឋបាលរាជធានី ខេត្ត សមាជិក
- ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត សមាជិក

ក្រៅពីសមាសភាពខាងលើនេះ រដ្ឋបាលរាជធានី ខេត្តអាចបន្ថែមសមាសភាពមកពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀត តាមការចាំបាច់ ជាសមាជិក។

«**គ.ក.ស.ក.**»នៃរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ មានសមាសភាពដូចខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាជាស្ត្រីដែលជ្រើសរើសដោយក្រុមប្រឹក្សា ប្រធាន
- សមាជិកក្រុមប្រឹក្សាដែលជ្រើសរើសដោយក្រុមប្រឹក្សា អនុប្រធាន
- អភិបាលរងជាស្ត្រីនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំនួន១រូប អនុប្រធាន
- នាយករងរដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន១រូប អនុប្រធាន
- ប្រធាន ឬអនុប្រធានការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម អនុប្រធានអចិន្ត្រៃយ៍
- ប្រធាន ឬអនុប្រធានការិយាល័យសុខាភិបាលស្រុក ក្រុង ខណ្ឌ សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យពាក់ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិក
- អធិការ ឬតំណាងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ សមាជិក
- ជំទប់ឬចៅសង្កាត់រងចំនួន១រូប ឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ សមាជិក

ក្រៅពីសមាសភាពខាងលើនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចបន្ថែមសមាសភាពមកពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀត តាមការចាំបាច់ ជាសមាជិក។

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិក«**គ.ក.ស.ក.**»។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាសាមី។

ក្នុងករណី ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំមានសមាជិកក្រុមប្រឹក្សាជាស្ត្រី ក្រុមប្រឹក្សាត្រូវជ្រើសរើសអភិបាលរងដែលជាស្ត្រីនៅក្នុងគណៈអភិបាលនៃរដ្ឋបាលសាមី ដើម្បីធ្វើជាប្រធាន«**គ.ក.ស.ក.**»។

**ប្រការ៥.-**

ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវខិតខំជានាឱ្យមានសមាជិកជាស្ត្រីសមស្របនៅក្នុង«**គ.ក.ស.ក.**»។

ក្នុងករណីមានការកែសម្រួលសមាសភាព«**គ.ក.ស.ក.**»ចាប់ពី៣រូបឡើងទៅ ត្រូវរៀបចំសេចក្តីសម្រេចជាថ្មីឡើងវិញ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ឱ្យស្របតាមនីតិវិធីនៃប្រកាសនេះ។

**ប្រការ៦.-**

«គ.ក.ស.ក.»អាចស្នើសុំក្រុមប្រឹក្សានៃរដ្ឋបាលនីមួយៗបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារតាមតម្រូវការនៃច្បាប់ លិខិតបទដ្ឋាននានា និងតាមការចាំបាច់ ដើម្បីជួយ«គ.ក.ស.ក.»ក្នុងការសិក្សាស្រាវជ្រាវ ឬលើកយោបល់លើបញ្ហានានាដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។

**ប្រការ៧.-**

តាមរយៈក្រុមប្រឹក្សានៃរដ្ឋបាលនីមួយៗ «គ.ក.ស.ក.»មានសិទ្ធិអញ្ជើញប្រធាន ឬតំណាងគណៈកម្មាធិការនានានៃរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ប្រធានមន្ទីរ អង្គភាព ក្រុមយុវជន និងកុមារ ដែលពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវជន កុមារ និងការងារសេវាសង្គមពាក់ព័ន្ធ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួមប្រជុំផ្តល់ព័ត៌មានពាក់ព័ន្ធដល់គណៈកម្មាធិការនានា។

**ប្រការ៨.-**

«គ.ក.ស.ក.»មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ ការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ ព្រមទាំងការងារសេវាសង្គមនានា
- ប្រមូល និងវិភាគព័ត៌មានឬទិន្នន័យដែលទាក់ទងនឹងយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិការបស់ក្រុមប្រឹក្សា
- ចូលរួមរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ដែលទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតនៃរដ្ឋបាលនីមួយៗ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការ សង្គមស៊ីវិល ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- សហការ និងផ្តល់ការគាំទ្រដល់«គ.ក.ស.ក.»របស់ក្រុមប្រឹក្សាប្រភេទផ្សេងៗទៀត ក្នុងការដោះស្រាយបញ្ហា ឬសំណូមពរ ឬសំណើនានាដែលក្រុមប្រឹក្សាប្រភេទផ្សេងនោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន
- លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាល អំពីមានការសម្របសម្រួលនានាដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងការដោះស្រាយនឹងការទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមពាក់ព័ន្ធ
- ជំរុញ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាដែលទាក់ទងនឹងសមភាព



ក្ក.៥

យេនឌ័រ ស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គម ដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

- ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍ដែលបានកើតមានពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ និងសកម្មភាពសេវាសង្គម និងមានវិធានការដើម្បីឆ្លើយតប
- ស្វែងរកការគាំទ្រដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរ អង្គភាពពាក់ព័ន្ធនានា អង្គការ សមាគម អ្នកផ្តល់សេវាក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវជន និងកុមារ
- ពិនិត្យមើលការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវជន និងកុមារ ជាពិសេសកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា ដើម្បីលើកអនុសាសន៍សម្រាប់ដោះស្រាយបញ្ហាទាំងនេះ
- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់ស្ត្រី យុវជន និងកុមារ ព្រមទាំងការងារសេវាសង្គមពាក់ព័ន្ធ
- គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែងដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

**ប្រការ៩.-**

ក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការដទៃទៀត ត្រូវយកចិត្តទុកដាក់គិតគូរលើអនុសាសន៍របស់«**គ.ក.ស.ក.**»និងធ្វើការសម្រេចដើម្បីចាត់វិធានការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ១០.-**

«**គ.ក.ស.ក.**»មានសិទ្ធិចូលរួមនៅក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល លើកលែងតែកិច្ចប្រជុំសម្ងាត់ ឬកិច្ចប្រជុំនានាដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ។

«**គ.ក.ស.ក.**»អាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងច្រើន២(ពីរ)រូប ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិបាល និងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា។ សមាជិកដែលត្រូវបានចាត់តាំងនេះមានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំនានាដូចគ្នានឹងសមាជិកដទៃទៀតក្នុងអង្គប្រជុំដែរ។

ក្នុងករណី សមាជិកដែលត្រូវបានចាត់តាំងនេះជាសមាជិកក្រុមប្រឹក្សា សមាជិកនេះមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់គណៈអភិបាលឡើយ។

ក្នុងការចូលរួមក្នុងកិច្ចប្រជុំខាងលើនេះ «**គ.ក.ស.ក.**»មានសិទ្ធិទទួលបាននូវរបៀបវារៈ និងឯកសារសម្រាប់កិច្ចប្រជុំនេះដូចសមាជិកអង្គប្រជុំដទៃទៀតដែរ។

**ប្រការ១១.-**

«គ.ក.ស.ក.»ត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាសាមី។

**ប្រការ១២.-**

របាយការណ៍ប្រចាំឆ្នាំរបស់«គ.ក.ស.ក.»ត្រូវរួមបញ្ចូលនូវ៖

- ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី យុវជន កុមារ និងអ្នកពាក់ព័ន្ធនឹងការងារសេវាសង្គមនានា ក្នុងការលើកកម្ពស់លើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- សមិទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការ និងអនុសាសន៍ ដើម្បីពង្រឹង«គ.ក.ស.ក.»
- អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រី យុវជន និងកុមារ នៅក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

**ជំពូកទី៣**

**តួនាទី និងភារកិច្ចរបស់ប្រធាន អនុប្រធាន និងសមាជិករបស់«គ.ក.ស.ក.»**

**ប្រការ១៣.-**

ប្រធាន«គ.ក.ស.ក.»មានតួនាទី និងភារកិច្ច៖

- ដឹកនាំកិច្ចប្រជុំរបស់«គ.ក.ស.ក.»។ ក្នុងករណី អវត្តមានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានគណៈកម្មាធិការដើម្បីដឹកនាំជំនួស
- ត្រួតពិនិត្យជារួមលើការដាក់បញ្ចូលសមភាពយេនឌ័រ និងតម្រូវការអាទិភាពស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា ទៅក្នុងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- ធានាថារាល់សំណូមពរ និងអនុសាសន៍របស់«គ.ក.ស.ក.»ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំ និងក្នុងកិច្ចការអនុវត្តរបស់គណៈកម្មាធិការនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិការបស់ក្រុមប្រឹក្សា
- ស្វែងរកការគាំទ្រ និងលើកទឹកចិត្តពីក្រុមប្រឹក្សា ដើម្បីធានាឱ្យមានថវិកាសមស្របនៅក្នុងមូលនិធិវិនិយោគរបស់ក្រុមប្រឹក្សាសម្រាប់គាំទ្រដល់គម្រោងឬសកម្មភាពសេវាសង្គម នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ជំរុញ និងលើកទឹកចិត្តសមាជិកផ្សេងទៀតរបស់«គ.ក.ស.ក.» ក្នុងការចូលរួមពិនិត្យ និងតាមដានសកម្មភាពរបស់«គ.ក.ស.ក.»ដែលបានអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ជួយក្រុមប្រឹក្សាក្នុងការកៀរគរធនធាន ដើម្បីឆ្លើយតបទៅនឹងការលើកកម្ពស់យេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមពាក់ព័ន្ធ ដែលបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល។

**ប្រការ១៤.-**

អនុប្រធាន«គ.ក.ស.ក.» មានតួនាទីនិងភារកិច្ច៖

- ចូលរួមក្នុងកិច្ចប្រជុំរបស់«គ.ក.ស.ក.»
- ជំនួសប្រធាន«គ.ក.ស.ក.» នៅពេលប្រធានអវត្តមាន តាមការផ្ទេរសិទ្ធិរបស់ប្រធាន

- សហការគាំទ្រដល់អនុប្រធានអចិន្ត្រៃយ៍ ក្នុងការជំរុញដាក់ចេញនូវសកម្មភាពរបស់«**គ.ក.ស.ក.**» ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តលើកិច្ចការរបស់គណៈកម្មាធិការ
- ផ្តល់យោបល់ និងផ្តល់ជំនាញបច្ចេកទេសនានាដល់ប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ទាក់ទងនឹងសកម្មភាពរបស់គណៈកម្មាធិការ
- ពិនិត្យរបាយការណ៍របស់«**គ.ក.ស.ក.**» មុនដាក់របាយការណ៍នេះជូនដល់អង្គប្រជុំ
- បំពេញរាល់កិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន«**គ.ក.ស.ក.**»។

**ប្រការ១៥.–**

អនុប្រធានអចិន្ត្រៃយ៍«**គ.ក.ស.ក.**» មានតួនាទី និងភារកិច្ច៖

- សម្របសម្រួលលើកិច្ចការរដ្ឋបាលប្រចាំថ្ងៃ និងការរៀបចំកិច្ចប្រជុំរបស់«**គ.ក.ស.ក.**»
- សិក្សា ស្រាវជ្រាវ និងលើកយោបល់ជូន«**គ.ក.ស.ក.**»អំពីការលើកកម្ពស់សមភាពយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា នៅក្នុងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- ជួយសម្របសម្រួល និងចូលរួមចំណែកក្នុងកិច្ចការពាក់ព័ន្ធ ដើម្បីធានាថាសមភាពយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា ត្រូវបានដាក់បញ្ចូលដោយពេញលេញក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- ជួយសមាជិក«**គ.ក.ស.ក.**»ក្នុងការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តសកម្មភាពទាក់ទងនឹងសមភាពយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងសកម្មភាពសេវាសង្គមនានា នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ព្រមទាំងរៀបចំរបាយការណ៍ជូន«**គ.ក.ស.ក.**»
- សហការ និងសម្របសម្រួលជាមួយនឹងសមាជិក«**គ.ក.ស.ក.**» និងអង្គភាពពាក់ព័ន្ធរបស់ក្រុមប្រឹក្សា ដើម្បីធានាការអនុវត្តនូវសេចក្តីសម្រេចរបស់គណៈកម្មាធិការ ដែលបានអនុមត័ដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព
- ចូលរួម និងសម្របសម្រួលឱ្យមានការប្រមូល និងវិភាគព័ត៌មានឬទិន្នន័យទាក់ទងនឹងយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមនានា ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចការរបស់«**គ.ក.ស.ក.**»
- បំពេញរាល់កិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន។

**ប្រការ១៦.–**

សមាជិក«**គ.ក.ស.ក.**» មានតួនាទី និងភារកិច្ច៖

- ចូលរួមនៅក្នុងកិច្ចប្រជុំនានារបស់«**គ.ក.ស.ក.**»
- ផ្តល់យោបល់ និងអនុសាសន៍ពាក់ពន្ធ័នឹងការលើកកម្ពស់ និងការជំរុញឱ្យមាននិរន្តរភាពនូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវជន និងកុមារ
- ចូលរួមក្នុងការប្រមូល និងវិភាគព័ត៌មានឬទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងបញ្ហាស្ត្រី យុវជន និងកុមារ ព្រមទាំងការងារសេវាសង្គម ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចការរបស់«**គ.ក.ស.ក.**»



ក.ន

- សម្របសម្រួល និងស្វែងរកមតិគាំទ្រដើម្បីដាក់បញ្ចូលសមភាពយេនឌ័រ តម្រូវការស្ត្រី យុវជន និងកុមារ និងការងារសេវាសង្គមពាក់ព័ន្ធ ទៅក្នុងវិស័យនីមួយៗនៃផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- ចូលរួមតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិនានា ដែលរួមមានអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីគេទ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារនៃការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទោសលើការជួញដូរមនុស្ស ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងតម្រូវការស្ត្រី យុវជន និងកុមារ ព្រមទាំងលើកកម្ពស់វិស័យសេវាសង្គមនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងដំណើរការពិនិត្យឡើងវិញ នូវការពិភាក្សា ការអនុម័តសេចក្តីព្រាងផែនការសកម្មភាព ត្រីមាស ឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការអនុវត្តការងារដែលទាក់ទងនឹងវិស័យនីមួយៗ របស់«**គ.ក.ស.ក.**»
- ចូលរួមក្នុងការរៀបចំរបាយការណ៍សកម្មភាពរបស់«**គ.ក.ស.ក.**»។

**ប្រការ១៧.-**

«**គ.ក.ស.ក.**»ត្រូវធ្វើការប្រជុំមុននឹងលើកយោបល់លើបញ្ហាណាមួយឬមួយចំនួន ជូនក្រុមប្រឹក្សា និងឬគណៈអភិបាល។

«**គ.ក.ស.ក.**» ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ ដោយភ្ជាប់ជាមួយនូវរបៀបវារៈ និងឯកសារពាក់ព័ន្ធ។ នៅក្នុងកិច្ចប្រជុំទាំងនេះ គណៈកម្មាធិការត្រូវ៖

- ពិនិត្យ និងអនុម័តលើផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់«**គ.ក.ស.ក.**»
- ពិភាក្សាលើដំណើរការ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងផែនការសកម្មភាព និងលើកជាអនុសាសន៍សម្រាប់ដោះស្រាយ
- ពិភាក្សាលើជំហានបន្ទាប់សម្រាប់អនុវត្តផែនការសកម្មភាពរបស់គណៈកម្មាធិការ
- ពិនិត្យ និងពិភាក្សាលើរបាយការណ៍ឬកំណត់ហេតុកិច្ចប្រជុំរបស់«**គ.ក.ស.ក.**» មុនដាក់ជូនក្រុមប្រឹក្សា។

ក្នុងករណីចាំបាច់ «**គ.ក.ស.ក.**»អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន «**គ.ក.ស.ក.**» ឬតាមសំណើរបស់ក្រុមប្រឹក្សា ឬតាមសំណើរបស់គណៈអភិបាល ឬតាមសំណើរបស់សមាជិកចំនួនមួយភាគបីនៃចំនួនសមាជិករបស់«**គ.ក.ស.ក.**»ទាំងមូល។

**ប្រការ១៨.-**

រាល់កិច្ចប្រជុំរបស់«**គ.ក.ស.ក.**»អាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកចូលរួមលើសពីពាក់កណ្តាលនៃចំនួនសមាជិករបស់«**គ.ក.ស.ក.**»ទាំងមូល ។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិក«**គ.ក.ស.ក.**»ទាំងមូល។ ក្នុងករណី ចំនួនសំឡេងស្មើគ្នា សំឡេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។

រាល់កិច្ចប្រជុំរបស់«**គ.ក.ស.ក.**» ត្រូវមានកំណត់ហេតុ។

**ប្រការ១៩.-**

រាល់កិច្ចប្រជុំរបស់«**គ.ក.ស.ក.**» ត្រូវរៀបចំជាសាធារណៈ។

«**គ.ក.ស.ក.**» អាចរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ងាត់បាន ដូចជាករណីរំលោភសេពសន្ថវៈ ការរំលោភបំពានលើកុមារ ដែលតម្រូវឱ្យមានកិច្ចការពារកិត្តិយស ឬសុវត្ថិភាពរបស់ បុគ្គល និងកិច្ចការដទៃទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីការរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ងាត់នេះ។

## ជំពូកទី៤

## យន្តការគាំទ្រ

**ប្រការ២០.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវផ្តល់ការគាំទ្រផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀតដល់«**គ.ក.ស.ក.**» ។

**ប្រការ២១.-**

«**គ.ក.ស.ក.**»នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត ត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងការឆ្លើយតបនឹងតម្រូវការ និងផ្តល់ការគាំទ្រនានាដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបញ្ហាស្ត្រី យុវជន និងកុមារ និងគម្រោងឬសកម្មភាពសេវាសង្គមនៅក្នុងឃុំ សង្កាត់នីមួយៗ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ២២.-**

ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌនេះ ត្រូវអនុវត្តជំនួសៈ

- ប្រកាសលេខ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្រកាសលេខ៧២៣ ប្រក ចុះថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការកែសម្រួលប្រការ៣នៃប្រកាសលេខ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ៣ឆ ១២ កេត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគ.ជ.អ.ប.
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ